ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៦៥..........សហវ.ប្រក

ប្រកាស

ស្តីពី

ការដាក់ឲ្យអនុវត្តវិភាគម្មវិធីពេញលេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខន ស.រកម.០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សម្រេច

ប្រការ១ ដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅក្រសួងចំនួន១០ គឺក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ, ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, ក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,និងក្រសួងសាធារណការនិងដឹកជញ្ជូន ដែលត្រូវចាប់ផ្តើមអនុវត្តសម្រាប់ការរៀបចំ និងការអនុវត្តថវិកាចាប់ពីឆ្នាំ២០១៥ តទៅ។

ប្រការ២ ក្រសួងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល នឹងត្រូវបានដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញ ជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៦តទៅ ដើម្បីសម្រេចគោលដៅនៃការដាក់ឲ្យគ្រប់ក្រសួងស្ថាប័ន ទាំងអស់ អនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២០។

ប្រការ៣ គ្រប់ក្រសួងស្ថាប័នមានភារកិច្ចដើម្បីអនុវត្តថវិកាកម្មវិធី ឲ្យទទួលបានជោគជ័យនិងប្រកប ដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ តាមទិសដៅនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា។

ប្រការ៤ ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួងស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ